# សិល្បៈនៃតំបន់ ហ្គោប៊ូស្ដាន

ហ្គោប៊ូស្ដាន ( Gobustan) គឺជាឈ្មោះ នៃតំបន់បេតិកភណ្ឌ និងស្ថានីយបុរាណវិទ្យាមួយ ដែលមានទីតាំងស្ថិតនៅក្នុងខេត្ត ហ្គោប៊ូស្ដាន នៃប្រទេសអាស៊ែបៃហ្សង់ និងមានចម្ងាយប្រមាណជាង ៤០គីឡូពីរាជធានី បាគូ។[១] គួរបញ្ជាក់ដែលថាបាគូ គឺជាផ្នែកមួយដ៏សំខាន់ពីការដឹកជញ្ជូនទំនិញតាមរយៈកំពង់ផែពាណិជ្ជកម្មពីតំបន់អាស៊ី ទៅអឺរ៉ុប តាមសមុទ្រ Caspian ឆ្លងកាត់ប្រទេសទួគី ចូលក្នុងតំបន់អឺរ៉ុប។[២] ឈូងសមុទ្របាគូ គឺជាតំបន់ដ៏សំខាន់សម្រាប់ការធ្វើនាវាចរឆ្លងកាត់ទៅ សមុទ្រ Caspian និងជាពិសេស ឈូងសមុទ្រនេះសំបូរទៅដោយប្រេងកាត។ លើសពីនេះ តំបន់នៃឈូងសមុទ្របាគូ គឺជាតំបន់ដែលសំបូរទៅដោយសម្បត្តិធម្មជាតិនៅក្នុងតំបន់ Caucasus ដែលស្ថិតនៅចន្លោះនឹងសមុទ្រខ្មៅ និងសមុទ្រ Caspian។[៣]

អាស៊ែបៃហ្សង់ គឺជាប្រទេសដែលស្ថិតនៅក្នុងអឺរ៉ុបខាងកើត និងអាស៊ីខាងលិច។ តំបន់ហ្គោប៊ូស្ដាន គឺមានទំហំផ្ទៃដីជាង ៣០៩៦ហិតា ដែលជាតំបន់ជ្រលងភ្នំខ្ពស់ៗ។ ស្ថានីយបុរាណវិទ្យា ហ្គោប៊ូស្ដានគឺបែងចែកជា៦សម័យកាល ដែលគិតចាប់ពីសម័យណេអូលីតិច (Neolithic) រហូតដល់សម័យកណ្ដាល (Middle Ages) ដែលបានបង្ហាញតាមរយៈសិល្បៈនៃគំនូរនៅលើថ្ម និងវត្ថុសិល្បៈផ្សេងៗទៀត។[៤] គំនូរទាំងនោះ គឺគូរនៅតាមជញ្ជាំងថ្មភ្នំ តាមល្អាង ក្នុងតំបន់ ហ្គោប៊ូស្ដាន។ ១.យុគថ្មរំលីង ( VIII millennia BC) ២.ចុងយុគថ្មរំលីង( VII-IV millenina BC) ៣. សម័យកាល Eneolithic ( V-III millenina BC) ៤. យុគសំរិទ្ធ (III-II millenina BC) ៥. យុគដែក (II-I millenina BC) ៦. សម័យកណ្ដាល (VIII-

[១] https://whc.unesco.org/en/list/1076/gallery/&maxrows=24

[២] https://en.unesco.org/silkroad/content/baku-baki

[៣] https://www.britannica.com/place/Caucasus

[៤] https://www.unesco.az/en/articles/material_cultural_heritage/qobustan

អត្ថបទដោយ៖ អេង តុលា

IX centuries and later)។[៥]

តាមរយៈរូបគំនូរទាំងនោះ បានបង្ហាញអំពីការរស់នៅរបស់មនុស្សសម័យបុរាណ និងជាភស្តុតាងដ៏សំខាន់នៃការវិវត្តិន៍បច្ចេកទេសក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស។ គំនូរទាំងអស់នោះ ក៏បានបង្ហាញពីការបរបាញ់សត្វ ដូចជា គោ ជ្រូក ខ្លាឃ្មុំ ដំរី ជាដើម។ គួរបញ្ជាក់ដែរថា តាមរយៈការស្រាវជ្រាវកន្លងមក ការបរបាញ់នៅតំបន់នេះ គឺមានអាយុកាលជាង 15,000-20,000 ឆ្នាំ។[៦]

នៅតំបន់នេះ គឺមានល្អាងជាច្រើន ដោយមួយចំនួនស្ថិតនៅក្នុងទឹកដីរបស់ប្រទេសរុស្ស៊ី និងនៅក្នុងប្រទេសអាស៊ែបៃហ្សង់ ដោយសារតែនៅ.ស.ទី២០ប្រទេសអាស៊ែបៃហ្សង់ គឺជាផ្នែកមួយនៃសហភាពសូវៀត រហូតដល់ចុងស.វ.ទី២០ ទើបប្រទេសនេះបានក្លាយជាសារធារណរដ្ឋ អាស៊ែបៃហ្សង់។

អ្នកស្រាវជ្រាវក៏បានសិក្សារូបគំនូរនៅក្នុងល្អាង Ana-zaga និងបានធ្វើកំណាយនៅទីនោះក្នុងឆ្នាំ ១៩៦៦ ដោយបានសិក្សាលើអាយុកាលដែលបានមកពីកាបូន១៤។ នៅទីនោះ អ្នកស្រាវជ្រាវក៏បានរកឃើញនូវភស្តុតាងដែលបង្ហាញពីស្រទាប់ដីចាស់ជាងគេ នៃតំបន់នេះ គឺស្ថិតនៅក្នុងយុគថ្មលំលីង (Neolithic)។[៧]

សរុបមកតំបន់ហ្គោប៊ូស្តាន គឺតំបន់សិល្បៈ និងវប្បធម៌ ដ៏ចំណាស់មួយក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់អាស៊ី ខាងលិច និងអឺរ៉ុប។ ពោលគឺមានការតាំងទីរស់នៅតាំងពីយុគថ្មរំលីង រហូតដល់យុគសំរិទ្ធ។ ជាពិសេស គំនូរនៅថ្មដែលជាភស្តុតាងដ៏សំខាន់ពីការវិវត្តន៍នៃឧបករណ៍បរបាញ់ និងបរិបទជុំវិញ នៃតំបន់នោះ៕

[៥] CLOTTES 2012.

[៦] CLOTTES 2012.

[៧] https://www.unesco.az/en/articles/material_cultural_heritage/qobustan

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ផែនដីនៃប្រទេស អាស៊ែបៃហ្សង់ និងស្ថានីយហ្គោប៊ូស្តាន

ប្រភព៖Unesco



រូបលេខ២៖តំបន់ ហ្គោប៊ូស្តាន

ប្រភព៖Unesco

អត្ថបទដោយ៖ អេង តុលា







រូបលេខ៣ ៤ និង ៥ ៖គំនូរនៅថ្ម ក្នុងស្ថានីយ ហ្គោប៊ូស្តាន
ប្រភព៖Unesco

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

https://whc.unesco.org/en/list/1076/gallery/&maxrows=24
https://en.unesco.org/silkroad/content/baku-baki
https://www.britannica.com/place/Caucasus
https://www.unesco.az/en/articles/material_cultural_heritage/qobustan
CLOTTES J. (dir.) 2012. — L'art pléistocène dans le monde / Pleistocene art of the world Actes du Congrès IFRAO, Tarascon-sur-Ariège, septembre 2010 – Symposium « Art pléistocène en Asie »

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION